# ការផ្ទេរចំណេះដឹងនិងរៀនភ្លេងខ្មែរបុរាណ

នាសម័យបុរាណ គ្រូភ្លេងខ្មែរទាំងឡាយ ដែលរកស៊ីបង្រៀនភ្លេងខ្មែរក្តី ភ្លេងពិណពាទ្យក្តី គេមិនដែលបង្ហាត់បង្រៀនសិស្សនៅលើគេហដ្ឋានរបស់គេទេ។ កូនសិស្សដែលស្ម័គ្រចិត្តរៀនភ្លេង តែងប្រាកលុយគ្នាដើម្បីនឹងសង់រោងនៅទីវាលណាមួយ ដែលគេបានកំណត់ទុកជាមុន។ ប៉ុន្តែ គ្រូខ្លះពោលថា កន្លែងសង់រោងរៀនភ្លេង ត្រូវនៅខាងកើត ឬនៅខាងត្បូងផ្ទះ ទើបល្អ។ មុននឹងសង់រោង គេធ្វើពិធីសុំទឹកសុំដី និងសែនក្រុងពាលី។ ចំពោះរឿងក្រុងពាលីនេះ តាមលោក គាំ ឌុំ អតីតបុគ្គលិកសារមន្ទីរចូលនិវត្តន៍ និងតាមឯកសារខ្លះរបស់ក្រុមទំនៀមទម្លាប់ថា រឿងរ៉ាវរបស់ក្រុងពាលី មានច្រើនណាស់ តាមការនិយាយតៗគ្នារបស់អ្នកស្រុក ដែលមានភាពវែងឆ្ងាយសម្រាប់អត្ថបទនេះ។ យ៉ាងណាមិញ ពិធីសែនក្រុងពាលី ដើម្បីសង់រោងរៀននេះ ក៏ដូចគ្នានឹងរបៀបសែនក្រុងពាលីលើកផ្ទះថ្មីដែរ។[១]

នៅក្នុងរោង មានបន្ទប់សម្រាប់គ្រូដេកនៅ មានទាំងគ្រែមួយធំនៅចំកណ្តាលរោង ដើម្បីតម្កល់គ្រឿងភ្លេងផង។ នៅប្របជញ្ជាំងរោងខាងលិច មានតុតម្កល់គ្រឿងពលីការសម្រាប់ឱ្យសិស្សយកទៀនធូប ទៅអុជបូជាព្រះពិស្ណុការរាល់ថ្ងៃមុននឹងប្រារព្ធរៀន។

នៅទីខាងកើតរោង ចម្ងាយមិនឆ្ងាយពីរោងប៉ុន្មាន គេធ្វើរានម៉ា (ខ្លះហៅថា រានកោរ) ៣ថ្នាក់ តម្កល់បាយសី ស្លាធម៌ ទឹកអប់ លាជ ផ្កា ដែលជាគ្រឿងបូជាចំពោះគ្រូភ្លេង។ គេរើសរកថ្ងៃល្អ ដើម្បីចូលរោង ផ្តើមរៀនភ្លេង។ លុះរកថ្ងៃបានហើយ គេធ្វើស្លាធម៌ទិស ដោតនៅទិសទាំង៨ ជុំវិញរោង។ កូនសិស្សទាំងប៉ុន្មាន ត្រូវប្រជុំគ្នាក្នុងរោង គ្រូធ្វើពិធីសែនព្រេនប្រោះព្រំសិស្សទាំងអស់ យកអំបោះជ័យទៅចងគ្រប់គ្រឿងភ្លេងទៀត។ រួចសិស្សត្រូវនាំគ្នាទៅអុជទៀនធូប ដោតនៅរានម៉ាដោយតាំងអធិដ្ឋានសុំឱ្យគ្រូចូលមកសណ្ឋិតឱ្យរៀនឆាប់ចេះឆាប់ចាំដូចសេចក្តីប្រាថ្នា។ បន្ទាប់ពីនោះមក គ្រូភ្លេងយកទ្រមកកូតបទអញ្ជើញគ្រូ ៣ បទ ថ្វាយគ្រូ រួចបង្គាប់ឱ្យសិស្សចូលទៅរៀបចំកន្លែងរៀនក្នុងរោងឱ្យបានត្រឹមត្រូវ។

កូនសិស្សទាំងឡាយដែលរៀនភ្លេង ត្រូវតមកន្លងគ្រឿងភ្លេង ជាដាច់ខាត។ បើដាច់ត្រណមនេះ នឹងត្រូវងងឹតភ្នែក ឬវង្វេងវិលវល់ រៀនមិនចេះចាំ ឬកើតមួម៉ៅក្តៅក្រហាយ

[១] ពេជ សល់ ១៩៧០: ៥៣

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ស្អប់ភ្លេងរៀនមិនកើត។ ត្រណមមួយទៀត គឺហាមផ្ដាច់មិនឱ្យស្រីចូលទៅក្នុងរោងនោះ បើមានស្រីណាលបលួចទៅ នឹងមានចុកចាប់សិស្សណាមួយមិនខាន។ ត្រណមទី៣ គឺកូនសិស្សទាំងឡាយ មិនត្រូវប៉ះពាល់នូវម្ហូបចំណី និងលុយកាក់ ដែលគេតម្កល់ទុកថ្វាយព្រះពិស្ណុការនោះឡើយ។ លុះគ្រប់មួយព្រហស្បតិ៍ (គឺពីព្រហស្បតិ៍មួយទៅព្រហស្បតិ៍មួយទៀត) ទើបត្រូវរើរុះរៀបចំគ្រឿងសក្ការៈនេះជាថ្មី។ ត្រណមនេះ បើមានសិស្សណាប្រព្រឹត្តល្មើស នឹងកើតហេតុផ្សេងៗ យ៉ាងធំមួយរំពេចមិនខាន ជួនមានភ្លើងឆេះរោង មានចោរលួចរបស់ទ្រព្យក្នុងរោង មានឈឺថ្កាត់ ឬអ្នករាជការអាជ្ញាធររករឿងរកហេតុឱ្យទាល់តែខានរៀនសូត្រ។

ឯវង្វាន់ក្នុងការបង្រៀន គេគិតត្រឹមមួយចេះ យកជាថ្លៃប៉ុន្មានៗ ទៅតាមកាលៈទេសៈនៃតម្លៃវត្ថុចិញ្ចឹមជីវិត។ ក្នុងសម័យមុន គឺទាល់តែរៀនចេះហើយ ទើបសិស្សប្រគល់វង្វាន់ជូនទៅគ្រូ។ តែក្រោយមក ដោយមានការមិនទៀងទាត់ ខាងផ្នែកសិស្ស គ្រូភ្លេងទារយកតម្លៃមុនជាស្រេច។

ពេលរៀន សិស្សទាំងអស់ត្រូវអង្គុយបត់ជើង ឈមមុខទៅរកពានម៉ា។ គ្រូរៀបចំសិស្សម្នាក់ៗឱ្យអង្គុយ ហើយឱ្យរៀនកាន់គ្រឿងភ្លេង គ្រូបង្គាប់សិស្សម្នាក់ៗ ឱ្យធ្វើដូចម្ដេចឱ្យតែឮសិន។ លុះសិស្សចេះកាន់ហើយ ទើបគ្រូបង្ហាញចាប់ខ្នង់។ មុននឹងរៀនលេងបទណាគ្រូធ្វើបទនោះនឹងមាត់ថា ណយ! ណយ! ឱ្យសិស្សថាតាម ឱ្យទាល់តែចេះបទនោះសិន ទើបយកគ្រឿងមកប្រាវឮដេញឬផ្លុំតាម។ គ្រូត្រូវកូតនាំមុខរង្វើល។ ដើម្បីឱ្យសិស្សដែលកាន់ទ្រ, ចាប៉ី, ខ្លុយ ដេញឬផ្លុំតាម។ បើសិស្សធ្វើតាមមិនត្រូវទេ ទើបគ្រូចាប់ដៃសិស្សបង្ហាញ។ ចំពោះអ្នកផ្លុំប៉ីឬខ្លុយ ដែលចេះតែផុតខ្យល់ មិនបានជាប់គ្នាវែងនោះ គ្រូបង្ហាត់សិស្សឱ្យបៀមទឹក រួចប្រឹងក្របួចមាត់ ធ្វើទឹកឱ្យបាញ់ទៅមុខ ឱ្យបានឆ្ងាយពីខ្លួន ប្រហែលពីរព្យាមដល់ពេលផ្លុំខ្លុយឬប៉ី ក៏ត្រូវបញ្ចេញខ្យល់ឱ្យវែងដូច្នេះដែរ ទើបរលាក់ខ្យល់បានពីរោះ ទាំងត្រូវហាត់ដកដង្ហើមតាមច្រមុះផង កុំដកតាមមាត់ ទើបមិនដាច់សំឡេង។ ពោលគឺរៀនគ្រប់គ្រងបច្ចេកទេសដកខ្យល់កុំឱ្យដាច់សូរ។[២]

---

[២] ពេជ សល់ ១៩៧០: ៥៦

កាលបើសិស្សរៀនចេះលេងខាងបុព្វកិច្ចស្ទាត់ហើយ ទើបគ្រូឱ្យសិស្សរៀនលេង «ស្តេចបទទាំង៤» (បទភ្លេងប្រពៃណី) ជាមុន គឺបទ នគររាជ, ស្តេចផ្ទំ, ខ្វាង, និងផាត់ជាយ។ បន្ទាប់ពីនេះទៅ ទើបគ្រូបង្ហាត់តាមចង្កោមពួកបទ។ នៅពេលរៀនលេងម្តងៗ អ្នកភ្លេងត្រូវរៀន «ស្តេចបទ» ជាមុនសិន តទៅ ទើបចាប់បទពាយរងដែលត្រូវរៀន។[៣]

ចំណែកភ្លេងពិណពាទ្យវិញ ការរៀនដំបូង មានរបៀបដូចគ្នានឹងភ្លេងខ្មែរដែរ។ តាមសេចក្តីឱ្យការណ៍ របស់លោក ឌួង អ៊ួច ដែលជាគ្រូភ្លេងពិណពាទ្យថា «ភ្លេងពិណពាទ្យ កាលណាសិស្សឈប់រៀន ត្រូវយកអន្ទូងគ្រប់យ៉ាង ទៅទុកលើធ្នើ ដែលរៀបរណ្តាប់គ្រូ»។ បទដែលត្រូវរៀនលេងជាដំបូង ក្នុងវង់ភ្លេងពិណពាទ្យគឺ ក្រៅណៃ, ក្រៅណក ខាត់ណក និងដើត ហើយត្រូវរៀនតែចង្វាក់មួយជាន់សិន។ លុះចេះស្ទាត់ហើយ ទើបរៀនចង្វាក់ពីរជាន់តទៅ។ បន្ទាប់ពីនោះមក ទើបរៀនបទពាយរងជាបន្ត។[៤]

បទសម្រាប់កំដរល្ខោន ត្រូវរៀនក្រោយគេបំផុត។ ពេលរៀនបទល្ខោន សិស្សត្រូវតមមិននិយាយគ្នានៅពេលកំពុងរៀន ហាមដើរកន្លង ឬហុចវត្ថុអ្វីរំលងគ្រឿងភ្លេងនោះ។ មុនពេលចូលរៀន សិស្សត្រូវចូលទៅអុជធូបមួយសសៃម្នាក់ ដោតនៅហ៊ឹងតំណាល់គ្រូ រួចទើបចាប់រៀនជាក្រោយ។

លុះរៀបចប់ហើយ គ្រូភ្លេងបង្គាប់ឱ្យសិស្សរៀបប្រដាប់សំពះគ្រូ មាន៖ ក្បាលជ្រូកស្ងោរ ១គូ, មាន់ស ១គូ, ទាស ១គូ, កង្កែបបោប ១គូ, ស្រាស ១ដប, ជម ៤, ប្រាក់ ៥ រៀល, សំពត់ស ១ហត្ថ, ទឹកអប់ ១គូ (២ដប), ផ្កាចំប៉ី ១មែក, និងលាជ ១ចាន ។[៥]

គេអុជធូបទៀនរួច ទើបយកអន្ទូងគ្រប់មុខមកប្រជុំ នៅត្រង់កណ្តាល។ សិស្សត្រូវលើកដៃឡើងប្រណម្យគ្រប់គ្នា ទើបគ្រូភ្លេងសូត្របាចលាជ បាចផ្កាចំប៉ីទៅលើប្រដាប់ភ្លេងទាំងរលាស់ទឹកប្រសិទ្ធពរឱ្យសិស្សជាការស្រេច។

នៅពេលដែលមានគេជួល ឬពឹងពរឱ្យទៅលេងម្តងៗ អ្នកភ្លេងត្រូវឱ្យអ្នកម្ចាស់បុណ្យ រៀបគ្រឿងក្លែម៤ អង្ករ១ចាន ទៀន១ដើម កាស៤ សំពត់គង់ផ្ទត់មួយ និងប្រាក់

---

[៣] ពេជ សល់ ១៩៧០: ៥៦

[៤] ពេជ សល់ ១៩៧០: ៥៧

[៥] ពេជ សល់ ១៩៧០: ៥៧-៥៨

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

មួយស៊ឹង (ឥឡូវនេះគេដាក់ ប្រាក់ ១រៀល) សម្រាប់បូជាព្រះពិស្ណុការភ្លេង។ បើមិនដូច្នេះទេ គេថាគ្រូមិនកាន់ លេងភ្លេងមិនពីរោះ។

## ឯកសារពិគ្រោះ

ពេជ សល់. (១៩៧០). *អំពីលំនាំសង្ខេបនៃភ្លេងខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។



គ្រូភ្លេងកំពុងតែបង្រៀនសិស្ស (ប្រភព៖ Phnom Penh Post)



គ្រូភ្លេងកំពុងតែបង្រៀនភ្លេងទៅកូនស្រី (ប្រភព៖ Youtube)

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង